ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ២៤-០២១-០០១ ភេ.ខ.ជាន

ថ្ងៃសុក្រ ១៣កើត ខែ ជេស្ឋ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ២០២១

# សារាចរណែនាំ
# ស្តីពី
# នីតិវិធីស្គាល់អត្តសញ្ញាណអតិថិជន និងការកំណត់ទំហំប្រាក់ប្រតិបត្តិការ សម្រាប់សេវាទូទាត់សងប្រាក់នៅកម្ពុជា

យោងប្រកាសលេខ ធ១៧.០២០.៣៧៩ ប្រ.ក ស្តីពីការដាក់ឱ្យប្រើប្រាស់វិធាននិងនីតិវិធីប្រព័ន្ធបាគង ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២០ និងយោងប្រកាសលេខ ធ១៧.០១៧.១៦១ ប្រ.ក ស្តីពីការគ្រប់គ្រងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៧ ធនាគារជាតិនៃកម្ពុជា សូមណែនាំអំពីការកំណត់ទំហំប្រាក់ប្រតិបត្តិការសម្រាប់សេវាទូទាត់សងប្រាក់នៅកម្ពុជា និងនីតិវិធីស្គាល់អត្តសញ្ញាណអតិថិជនដែលគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ត្រូវអនុវត្តឱ្យបានសមស្របនិងងាយស្រួលសម្រាប់អតិថិជនក្នុងការចុះឈ្មោះប្រើប្រាស់។ ដោយសារភាពខុសគ្នានៃកម្រិតហានិភ័យរបស់អតិថិជននីមួយៗ នីតិវិធីនៃការស្គាល់អត្តសញ្ញាណអតិថិជនត្រូវបានកំណត់ដូចខាងក្រោម៖

## ១. ប្រតិបត្តិការរវាងគណនីបាគង និងគណនីបាគង

| ចំណាត់ថ្នាក់អតិថិជន | ទំហំប្រាក់ប្រតិបត្តិការក្នុងមួយថ្ងៃ |
|---|---|
| **ក. អតិថិជនថ្នាក់ដំបូង** (Basic Customer) ៖ អតិថិជនចុះឈ្មោះប្រើប្រាស់ដោយខ្លួនឯងតាមអនឡាញ ឬតាមកម្មវិធីទូទាត់ទូរស័ព្ទចល័ត។ ប៉ុន្តែអតិថិជនពុំបានបំពេញព័ត៌មានត្រឹមត្រូវតាមការតម្រូវរបស់គ្រឹះស្ថានសមាជិកនៅឡើយ។ ឯកសារតម្រូវអប្បបរមាសម្រាប់ចុះឈ្មោះមានត្រឹមតែលេខទូរស័ព្ទ។ | ២លានរៀល និង ៥០០ដុល្លារអាមេរិក |
| **ខ. អតិថិជនថ្នាក់មធ្យម** (Partial KYC) ៖ អតិថិជនចុះឈ្មោះប្រើប្រាស់ដោយខ្លួនឯងតាមអនឡាញ ឬតាមកម្មវិធីទូទាត់ទូរស័ព្ទចល័ត ដោយបំពេញព័ត៌មានត្រឹមត្រូវតាមការតម្រូវរបស់គ្រឹះស្ថានសមាជិក ប៉ុន្តែពុំទាន់បានផ្ទៀងផ្ទាត់តាមនីតិវិធីស្គាល់អតិថិជនរបស់គ្រឹះស្ថានសមាជិកនៅឡើយ។ ឯកសារតម្រូវអប្បបរមាសម្រាប់ចុះឈ្មោះមានដូចជា៖<br>- លេខទូរស័ព្ទ<br>- ថតរូបសែលហ្វី<br>- ថតរូបអត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន (ដែលមានសុពលភាព)។ | ១២លានរៀល និង ៣.០០០ដុល្លារអាមេរិក |



ប្រអប់សំបុត្រលេខ ២៥, ឡូតិ៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

| | |
|---|---|
| **គ. អតិថិជនពេញលេញ (Full KYC)** ៖ អតិថិជនចុះឈ្មោះប្រើប្រាស់ដោយខ្លួនឯងតាមអនឡាញ ឬតាមកម្មវិធីទូទាត់ទូរស័ព្ទចល័ត ឬនៅតាមបញ្ជរគ្រឹះស្ថាន និងបានផ្ទៀងផ្ទាត់តាមនីតិវិធីស្គាល់អតិថិជនរបស់គ្រឹះស្ថានសមាជិករួចរាល់។ ឯកសារតម្រូវអប្បបរមាសម្រាប់ចុះឈ្មោះមានដូចជា៖<br>- លេខទូរស័ព្ទ<br>- ថតរូបសែលហ្វី<br>- ថតរូបអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន (ដែលមានសុពលភាព)។ | ៨០លានរៀល និង<br>១០.០០០ដុល្លារអាមេរិក |

## ២. ប្រតិបត្តិការរវាងគណនីបាគង និងគណនីធនាគារ/គណនីអ៊ីវ៉ាឡេត

| ចំណាត់ថ្នាក់អតិថិជន | ទំហំប្រាក់ប្រតិបត្តិការក្នុងមួយថ្ងៃ |
|---|---|
| **ក. អតិថិជនថ្នាក់ដំបូង (Basic Customer)** ៖ អតិថិជនចុះឈ្មោះប្រើប្រាស់ដោយខ្លួនឯងតាមអនឡាញ ឬតាមកម្មវិធីទូទាត់ទូរស័ព្ទចល័ត។ ប៉ុន្តែអតិថិជនពុំបានបំពេញព័ត៌មានត្រឹមត្រូវតាមការតម្រូវរបស់គ្រឹះស្ថានសមាជិកនៅឡើយ។ ឯកសារតម្រូវអប្បបរមាសម្រាប់ចុះឈ្មោះមានត្រឹមតែលេខទូរស័ព្ទ។ | ២លានរៀល និង<br>៥០០ដុល្លារអាមេរិក |
| **ខ. អតិថិជនថ្នាក់មធ្យម (Partial KYC)** ៖ អតិថិជនចុះឈ្មោះប្រើប្រាស់ដោយខ្លួនឯងតាមអនឡាញ ឬតាមកម្មវិធីទូទាត់ទូរស័ព្ទចល័ត ដោយបំពេញព័ត៌មានត្រឹមត្រូវតាមការតម្រូវរបស់គ្រឹះស្ថានសមាជិក ប៉ុន្តែពុំទាន់បានផ្ទៀងផ្ទាត់តាមនីតិ-វិធីស្គាល់អតិថិជនរបស់គ្រឹះស្ថានសមាជិកនៅឡើយ។ ឯកសារតម្រូវអប្បបរមាសម្រាប់ចុះឈ្មោះមានដូចជា៖<br>- លេខទូរស័ព្ទ<br>- ថតរូបសែលហ្វី<br>- ថតរូបអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន (ដែលមានសុពលភាព)។ | ១២លានរៀល និង<br>៣.០០០ដុល្លារអាមេរិក |
| **គ. អតិថិជនពេញលេញ (Full KYC)** ៖ អតិថិជនចុះឈ្មោះប្រើប្រាស់ដោយខ្លួនឯងតាមអនឡាញ ឬតាមកម្មវិធីទូទាត់ទូរស័ព្ទចល័ត ឬនៅតាមបញ្ជរគ្រឹះស្ថាន និងបានផ្ទៀងផ្ទាត់តាមនីតិវិធីស្គាល់អតិថិជនរបស់គ្រឹះស្ថានសមាជិករួចរាល់។ ឯកសារតម្រូវអប្បបរមាសម្រាប់ចុះឈ្មោះមានដូចជា៖<br>- លេខទូរស័ព្ទ<br>- ថតរូបសែលហ្វី<br>- ថតរូបអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន (ដែលមានសុពលភាព)។ | ៨០លានរៀល និង<br>១០.០០០ដុល្លារអាមេរិក |

## ៣. ប្រតិបត្តិការរវាងគណនីធនាគារ និងគណនីធនាគារ តាមរយៈប្រព័ន្ធបាគង (Backbone)

| ចំណាត់ថ្នាក់អតិថិជន | ទំហំប្រាក់ប្រតិបត្តិការក្នុងមួយថ្ងៃ |
|---|---|
| ចំពោះចំណាត់ថ្នាក់អតិថិជនតាមប្រព័ន្ធបាគង (Backbone) ជាអតិថិជនពេញលក្ខណ: (Full KYC) ដោយសារអតិថិជនបានចុះឈ្មោះប្រើប្រាស់ត្រឹមត្រូវ និងបានធ្វើការផ្ទៀងផ្ទាត់តាមនីតិវិធីស្គាល់អតិថិជនរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុក្នុងការបើកគណនីនៅធនាគាររួចរាល់ហើយ។ | ២០០លានរៀល និង<br>៥០.០០០ដុល្លារអាមេរិក |

## ៤. ប្រតិបត្តិការរវាងគណនីអ៊ីវ៉ាឡេត និងគណនីអ៊ីវ៉ាឡេត/គណនីធនាគារ

| ចំណាត់ថ្នាក់អតិថិជន | ទំហំប្រាក់ប្រតិបត្តិការក្នុងមួយថ្ងៃ |
|---|---|
| **ក. អតិថិជនថ្នាក់ដំបូង (Basic Customer)៖** អតិថិជនចុះឈ្មោះប្រើប្រាស់ដោយខ្លួនឯងតាមអនឡាញ ឬតាមកម្មវិធីទូទាត់ទូរស័ព្ទចល័ត។ ប៉ុន្តែអតិថិជនពុំបានបំពេញព័ត៌មានត្រឹមត្រូវតាមការតម្រូវរបស់គ្រឹះស្ថានសមាជិកនៅឡើយ។ ឯកសារតម្រូវអប្បបរមាសម្រាប់ចុះឈ្មោះមានត្រឹមតែលេខទូរស័ព្ទ។ | ២លានរៀល និង ៥០០ដុល្លារអាមេរិក |
| **ខ. អតិថិជនថ្នាក់មធ្យម (Partial KYC)៖** អតិថិជនចុះឈ្មោះប្រើប្រាស់ដោយខ្លួនឯងតាមអនឡាញ ឬតាមកម្មវិធីទូទាត់ទូរស័ព្ទចល័ត ដោយបំពេញព័ត៌មានត្រឹមត្រូវតាមការតម្រូវរបស់គ្រឹះស្ថានសមាជិក ប៉ុន្តែពុំទាន់បានផ្ទៀងផ្ទាត់តាមនីតិវិធីស្គាល់អតិថិជនរបស់គ្រឹះស្ថានសមាជិកនៅឡើយ។ ឯកសារតម្រូវអប្បបរមាសម្រាប់ចុះឈ្មោះមានដូចជា៖<br>- លេខទូរស័ព្ទ<br>- ថតរូបសែលហ្វី<br>- ថតរូបអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន (ដែលមានសុពលភាព)។ | ១២លានរៀល និង ៣.០០០ដុល្លារអាមេរិក |
| **គ. អតិថិជនពេញលេញ (Full KYC)៖** អតិថិជនចុះឈ្មោះប្រើប្រាស់ដោយខ្លួនឯងតាមអនឡាញ ឬតាមកម្មវិធីទូទាត់ទូរស័ព្ទចល័ត ឬនៅតាមបញ្ជរគ្រឹះស្ថាន និងបានផ្ទៀងផ្ទាត់តាមនីតិវិធីស្គាល់អតិថិជនរបស់គ្រឹះស្ថានសមាជិករួចរាល់។ ឯកសារតម្រូវអប្បបរមាសម្រាប់ចុះឈ្មោះមានដូចជា៖<br>- លេខទូរស័ព្ទ<br>- ថតរូបសែលហ្វី<br>- ថតរូបអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន (ដែលមានសុពលភាព)។ | ៤០លានរៀល និង ១០.០០០ដុល្លារអាមេរិក |

សារាចរណែនាំនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ទេសាភិបាល**

**ជា ចាន់តូ**

**កន្លែងទទួល៖**

- អគ្គលេខាធិការដ្ឋាន
- អគ្គនាយកដ្ឋានត្រួតពិនិត្យ
- អគ្គនាយកដ្ឋានបច្ចេកទេស
- អគ្គបេឡា
- អគ្គាធិការដ្ឋាន
- គ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ